**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

លេខ.....០១០..........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# លក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមការអនុម័តនៃសម័យប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដែលមិនមែនជាមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈ (ហៅកាត់ថាមន្ត្រីលក្ខន្តិកៈ) ដូចមានចែងក្នុង អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការ គ្រប់គ្រងមន្ត្រីលក្ខន្តិកៈ និងការអភិវឌ្ឍធនធានមនុស្សរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



អគារ១៦៨F ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#168F, Street 598, Sangkat Chrang Chamres 1, Khan Russei Keo, Phnom Penh, Cambodia
ទូរស័ព្ទ: (+៨៥៥) ២៣ ៩៩៩ ៧០០
Phone: (+855) 23 999 700

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីលក្ខន្តិកៈ ដែលមានឧបនិស្ស័យសម្រាប់បំពេញមុខតំណែង និងការងារផ្សេងៗក្នុងក្របខណ្ឌការងាររបស់ **អ.ស.ហ.**។

## ជំពូកទី២
## ស្ថាប័នគ្រប់គ្រង

**ប្រការ៣.-**

មន្ត្រីលក្ខន្តិកៈត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ។

## ជំពូកទី៣
## ប្រភេទ និងមុខតំណែងរបស់មន្ត្រីលក្ខន្តិកៈ

**ប្រការ៤.-**

មន្ត្រីលក្ខន្តិកៈមាន ២ (ពីរ) ប្រភេទ÷

- អនុមន្ត្រី
- មន្ត្រីក្រមការ។

**ប្រការ៥.-**

អនុមន្ត្រី ជាមន្ត្រីដែលមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងខ្ពស់បំផុតត្រឹមជាអនុប្រធាននាយកដ្ឋាន ឬថ្នាក់ស្មើដែលមានក្នុងអង្គការលេខនៃរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**។

អនុមន្ត្រី ត្រូវបានបែងចែកជា ៣ (បី) ថ្នាក់ រួមមាន អនុមន្ត្រីកម្រិត ១ អនុមន្ត្រីកម្រិត ២ និង អនុមន្ត្រីកម្រិត ៣។

**ប្រការ៦.-**

មន្ត្រីក្រមការនៃ **អ.ស.ហ.** មាន ៣ (បី) ថ្នាក់ និងមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងដូចខាងក្រោម÷

- នាយក្រមការ ជាមន្ត្រីដែលមានឧបនិស្ស័យសម្រាប់កាន់មុខដំណែងខ្ពស់បំផុតត្រឹមជាប្រធានការិយាល័យ ឬថ្នាក់ស្មើដែលមានក្នុងអង្គការលេខនៃរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**
- ក្រមការដើមខ្សែ ជាមន្ត្រីដែលមានឧបនិស្ស័យសម្រាប់កាន់មុខដំណែងខ្ពស់បំផុតត្រឹមជាជាអនុប្រធានការិយាល័យ ឬថ្នាក់ស្មើដែលមានក្នុងអង្គការលេខនៃរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**
- ក្រមការ ជាមន្ត្រីគ្មានមុខដំណែងណាមួយក្នុងអង្គការលេខនៃរចនាសម្ព័ន្ធអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**។

## ជំពូកទី៤
## ការជ្រើសរើសមន្ត្រី

**ប្រការ៧.-**

ការជ្រើសរើសមន្ត្រីចូលក្នុងក្របខណ្ឌមន្ត្រីលក្ខន្តិកៈ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងជាសាធារណៈ លើកលែងតែមានករណីចាំបាច់តាមការកំណត់របស់ប្រធាន **អ.ស.ហ.**។

**ប្រការ៨.-**

បេក្ខជនដែលចូលរួមការប្រឡងប្រជែងជាមន្ត្រីលក្ខន្តិកៈ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- មានសញ្ជាតិជាខ្មែរ
- មានអាយុច្រើនបំផុត ៤៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មានសញ្ញាបត្រទាបបំផុត បរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើតាមមុខជំនាញដែល **អ.ស.ហ.** ត្រូវការចាំបាច់
- មិនបានប្រាសចាកសិទ្ធិខាងរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ
- មិនធ្លាប់មានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- ត្រូវមានសុខភាពល្អ និងគ្រប់គ្រាន់ក្នុងការបំពេញការងារ។

ការជ្រើសរើសមន្ត្រីដើម្បីបញ្ចូលជាមន្ត្រីលក្ខន្តិកៈក្នុងរចនាសម្ព័ន្ធនៃអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ព្រមទាំងសមាសភាពគណៈកម្មការប្រឡងជ្រើសរើស ត្រូវកំណត់ដោយប្រធាន **អ.ស.ហ.** តាមសំណើរបស់និយ័តករ និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**។ បែបបទលម្អិតនៃការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈ ត្រូវកំណត់ដោយគណៈកម្មការប្រឡងជ្រើសរើស ។

## ជំពូកទី៥
## ការសាកល្បង និងការទទួលស្គាល់មន្ត្រីលក្ខន្តិកៈ

**ប្រការ៩.-**

បេក្ខជនដែលត្រូវបានជ្រើសរើសតាមប្រការខាងលើ ត្រូវធ្វើកម្មសិក្សាសាកល្បងការងាររយៈពេល **៣ (បី) ខែ** ក្នុងឋានៈជាមន្ត្រីកម្មសិក្សា មុននឹងទទួលស្គាល់ជាមន្ត្រីលក្ខន្តិកៈ។ ក្នុងករណីចាំបាច់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ឬអគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ឬប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** អាចសម្រេចឱ្យមន្ត្រីកម្មសិក្សាបន្តរយៈពេលសាកល្បងអតិបរមាត្រឹម **៣ (បី) ខែ**ទៀត។

មន្ត្រីកម្មសិក្សាអាចត្រូវបានចាត់ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាបានក្នុងករណីចាំបាច់។

**ប្រការ១០.-**

មន្ត្រីកម្មសិក្សាណាដែលមិនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬត្រូវបានពិនិត្យឃើញថារបៀបធ្វើការមានភាពខ្ជីខ្ជា គ្មានការទទួលខុសត្រូវលើការងារ គ្មានកម្លាំងនឹងបំពេញមុខងាររបស់ខ្លួនបាន ឬមកបំពេញការងារមិនទៀងទាត់ ដោយអាក់ខានមកធ្វើកម្មសិក្សាសរុបលើសពី **១៥ (ដប់ប្រាំ)** ថ្ងៃនៃថ្ងៃធ្វើការ ដោយគ្មានមូលហេតុសមរម្យ អាចត្រូវបញ្ឈប់មិនឱ្យធ្វើកម្មសិក្សាបន្ទាប់ពីមានការវាយតម្លៃដោយអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ឬអគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ឬប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**។

មន្ត្រីដែលបានបញ្ចប់កម្មសិក្សាដោយជោគជ័យ ត្រូវបានទទួលស្គាល់ជាមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី៦
## ការតែងតាំង ការដំឡើងថ្នាក់ និងការផ្លាស់ប្តូរប្របែតន

**ប្រការ១១.-**

មន្ត្រីលក្ខន្តិកៈអាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដែលសមស្រប ក្រោយពេលត្រូវបានទទួលស្គាល់ជាមន្ត្រីលក្ខន្តិកៈដោយប្រកាសរបស់ប្រធាន **អ.ស.ហ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ឬអគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ឬប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** ។

**ប្រការ១២.-**

មន្ត្រីលក្ខន្តិកៈ អាចត្រូវរៀបចំដំឡើងថ្នាក់តាមការប្រឡងផ្ទៃក្នុង ក្នុងចំណោមមន្ត្រីដែលមានអតីតភាពការងារយ៉ាងតិច ២ (ពីរ) ឆ្នាំ និងមានលក្ខណសម្បត្តិជាមូលដ្ឋានដូចខាងក្រោម÷

- មានឆន្ទៈបម្រើការងារនៅអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**
- មានសមត្ថភាព និងសម្រេចបានល្អនូវភារកិច្ចដែលបានប្រគល់ឱ្យ
- មានការទទួលខុសត្រូវចំពោះការងារ
- គោរពវិន័យការងារបានត្រឹមត្រូវ
- មានកិរិយាមាយាទ និងសីលធម៌ល្អ ដែលមិនធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ **អ.ស.ហ.**
- មានសាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមន្ត្រី បុគ្គលិក និងសាធារណជន។

ការដំឡើងថ្នាក់ត្រូវធ្វើឡើងដោយម្តងមួយថ្នាក់ៗ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ ប្រធាន **អ.ស.ហ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ឬអគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ឬប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**។ ការដំឡើងថ្នាក់មន្ត្រីលក្ខន្តិកៈត្រូវធ្វើឡើងដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

**ប្រការ១៣.-**

ការផ្លាស់ប្តូរប្រភេទមន្ត្រីលក្ខន្តិកៈទៅក្នុងប្រភេទដែលខ្ពស់ជាង ត្រូវធ្វើឡើងតាមរយៈការប្រឡងជ្រើសរើសផ្ទៃក្នុង ឬតាមរយៈការសម្រេចដោយប្រធាន **អ.ស.ហ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ឬអគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ឬប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**។

មន្ត្រីលក្ខន្តិកៈអាចត្រូវបានផ្លាស់ប្តូរទៅក្នុងប្រភេទអនុមន្ត្រី ចំពោះមន្ត្រីទាំងឡាយណាដែលបានឡើងដល់ថ្នាក់នាយក្រមការនៃប្រភេទមន្ត្រីក្រមការរបស់ **អ.ស.ហ.**។

ការផ្លាស់ប្តូរប្រភេទមន្ត្រីលក្ខន្តិកៈ ត្រូវធ្វើឡើងដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

**ប្រការ១៤.-**

កម្រិតប្រាក់បៀវត្សរបស់មន្ត្រីកម្មសិក្សាត្រូវកំណត់ដោយប្រធាន **អ.ស.ហ.**។

ប្រាក់បៀវត្ស និងលាភការសម្រាប់មន្ត្រីនៅក្នុងថ្នាក់ ឬប្រភេទនីមួយៗនៃលក្ខន្តិកៈរបស់ **អ.ស.ហ.** ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី៧

## ស្ថានភាពការងារ

**ប្រការ១៥.-**

របបកំណត់ស្តីពីថិរវេលាធ្វើការឈប់សម្រាក និងវិន័យការងាររបស់មន្ត្រីលក្ខន្តិកៈ ត្រូវកំណត់ក្នុងប្រកាសស្តីពីការដាក់ឱ្យអនុវត្តបទបញ្ជាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងមន្ត្រី **អ.ស.ហ.**។

**ប្រការ១៦-**

ការផ្លាស់ប្តូរ ការព្យួរ ការលាលែង ការបញ្ឈប់ពីការងារ ការដាក់ចូលក្នុងស្ថានភាពបាត់បង់សម្បទាវិជ្ជាជីវៈ ការដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់នឹងត្រូវកំណត់ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.** ។

**ប្រការ១៧.-**

មន្ត្រីលក្ខន្តិកៈណាដែលកំពុងជាប់ការចោទប្រកាន់ពីបទមជ្ឈិម ឬបទឧក្រិដ្ឋនៅតុលាការអាចត្រូវបានព្យួរការងារក្នុងករណីចាំបាច់។



✓

ក្នុងករណីមន្ត្រីលក្ខន្តិកៈ ត្រូវបានព្យួរការងារដោយព្យួរទាំងបៀវត្ស និងលាភការផ្សេងៗ មន្ត្រីរូបនោះត្រូវបានទទួលឱ្យចូលធ្វើការនៅ **អ.ស.ហ.** វិញភ្លាម ដោយគិតបញ្ចូលពីអតីតភាព ថ្នាក់ ប្រភេទ សោធននិវត្តន៍ ទទួលបៀវត្ស លាភការ និងប្រតិលកម្ម ប្រសិនបើតុលាការប្រកាសជាស្ថាពរពីភាពស្អាតស្អំរបស់មន្ត្រីនោះ។

**ប្រការ១៨.-**

ការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋចំពោះមន្ត្រីលក្ខន្តិកៈ ទោះបីជាករណីព្យួរទោសក៏ដោយ អាចនឹងបណ្តាលឱ្យមានការបញ្ឈប់ពីការងារចំពោះមន្ត្រីនោះគិតចាប់ពីថ្ងៃដែលសាលក្រម ឬសាលដីកាចូលជាស្ថាពរ។

**ប្រការ១៩.-**

មន្ត្រីលក្ខន្តិកៈមិនត្រូវអនុវត្តមុខងារ និង/ឬសកម្មភាពទាំងឡាយណាដែលមានវិសមិតភាព និងទំនាស់ផលប្រយោជន៍ជាមួយមុខងារ និងតួនាទីជាមន្ត្រីរបស់ **អ.ស.ហ.** នោះទេ។

**ប្រការ២០.-**

មន្ត្រីលក្ខន្តិកៈត្រូវមានអព្យាក្រឹតភាពក្នុងមុខងារ និង/ឬសកម្មភាពការងារ និងហាមឃាត់ជាដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួននិងសម្ភារៈរបស់ **អ.ស.ហ.** ដើម្បីបម្រើសកម្មភាពនយោបាយដូចខាងក្រោម÷

១-ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ

២-ធ្វើការដើម្បីផលប្រយោជន៍ដល់គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ។

ការប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ចាត់ទុកជាកំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ និងត្រូវទទួលទណ្ឌកម្មតាមការសម្រេចរបស់ក្រុមប្រឹក្សាវិន័យនៃ **អ.ស.ហ.**។

## ជំពូកទី៤
## វិន័យការងារ

**ប្រការ២១.-**

មន្ត្រីលក្ខន្តិកៈនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ក្នុងករណីប្រព្រឹត្តល្មើសទៅនឹងវិន័យដូចដែលមានចែងក្នុងប្រកាសស្តីពីការដាក់ឱ្យអនុវត្តបទបញ្ជាផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងមន្ត្រី **អ.ស.ហ.** និងក្នុងប្រកាសនេះ ។

ទណ្ឌកម្មខាងវិន័យមានដូចតទៅ÷

១-ទណ្ឌកម្មថ្នាក់ទី ១

ក. ស្តីបន្ទោស

ខ. ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ. ផ្លាស់ប្តូរការងារដោយបង្ខំតាមវិធានការខាងវិន័យ

ឃ. លុបឈ្មោះមិនឱ្យឡើងថ្នាក់ ឬផ្លាស់ប្តូរប្រភេទ។

២-ទណ្ឌកម្មថ្នាក់ទី ២

ក. ដាក់ឱ្យនៅទំនេរគ្មានបៀវត្ស មិនលើសពី **១ (មួយ) ឆ្នាំ**

ខ. បន្ថយមួយថ្នាក់ ឬច្រើនថ្នាក់

គ. ដាក់ឱ្យចូលនិវត្តន៍មុនកំណត់

ឃ. បញ្ឈប់ពីការងារ។

**ប្រការ២២.-**

រាល់ទណ្ឌកម្មខាងវិន័យថ្នាក់ទី ១ ត្រូវសម្រេចឡើងដោយនិយ័តករ និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**។ ចំពោះទណ្ឌកម្មថ្នាក់ទី ២ ត្រូវមានការសម្រេចដោយក្រុមប្រឹក្សាវិន័យ។

មន្ត្រីដែលរងទណ្ឌកម្មខាងវិន័យមានសិទ្ធិដូចខាងក្រោម÷

- សិទ្ធិសុំមើលសំណុំរឿងផ្ទាល់ខ្លួន
- សិទ្ធិសុំអាងសាក្សី
- សិទ្ធិជ្រើសរើសតំណាងការពារខ្លួន
- សិទ្ធិពន្យល់ដោះសារជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

នីតិវិធីនៃការអនុវត្តវិន័យនឹងត្រូវកំណត់ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី៩
## ការចូលនិវត្តន៍

**ប្រការ២៣.-**

មន្ត្រីលក្ខន្តិកៈត្រូវដាក់ឱ្យចូលនិវត្តន៍ជាកំហិតពេលដល់អាយុ **៦០ ឆ្នាំ** ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ឬអគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ឬប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**។ របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈនឹងកំណត់ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

**ប្រការ២៤.-**

មន្ត្រីលក្ខន្តិកៈមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ស្របតាមអតីតភាពការងារដែលនឹងត្រូវកំណត់ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី១០
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ២៥.-**

មន្ត្រីលក្ខន្តិកៈត្រូវទទួលប្រាក់ឧបត្ថម្ភធានារ៉ាប់រងសង្គម និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត តាមការកំណត់ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

**ប្រការ២៦.-**

អង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** អាចធ្វើការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាដើម្បីបំពេញការងារក្នុងរចនាសម្ព័ន្ធរបស់ខ្លួន បន្ទាប់ពីមានការអនុញ្ញាតជាមុនពីប្រធាន **អ.ស.ហ.**។ មន្ត្រីជាប់កិច្ចសន្យាត្រូវទទួលបាននូវប្រាក់បៀវត្ស និងត្រូវអនុវត្តតាមលក្ខណដូចមានកំណត់ក្នុងកិច្ចសន្យាជាមួយអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**ប្រការ២៧.-**

មន្ត្រី និងបុគ្គលិកកិច្ចសន្យាដែលកំពុងបម្រើការងារនៅក្នុងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.** ត្រូវធ្វើសមាហរណកម្មជាមន្ត្រីលក្ខន្តិកៈដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

មន្ត្រីលក្ខន្តិកៈនៃនិយ័តករមូលបត្រកម្ពុជាត្រូវធ្វើសមាហរណកម្មជាមន្ត្រីលក្ខន្តិកៈ **អ.ស.ហ.** ដោយប្រកាសរបស់ប្រធាន **អ.ស.ហ.**។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**ប្រការ២៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៩.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** អគ្គនាយកនៃនិយ័តករពាក់ព័ន្ធ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** និងអង្គភាពចំណុះឱ្យ **អ.ស.ហ.** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អនុប្រធាន និងសមាជិកក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៩
- "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ